អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# សំណងដល់ជនរងគ្រោះនៃរបបខ្មែរក្រហមទទួលបានការគាំទ្រយ៉ាងទូលំទូលាយ

រហូតមកដល់ពេលនេះ មានការគាំទ្រយ៉ាងទូលំទូលាយចំពោះគម្រោងសំណង ដែលបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ គម្រោងសំណងទាំងនេះនឹងផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យពី ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩។ អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កំពុងតែខិតខំប្រឹងប្រែងដឹកនាំកិច្ចការនេះ ប្រកបដោយភាពច្នៃប្រឌិត ដើម្បីជួសជុលព្យសនកម្មរបស់ជនរងគ្រោះដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ អង្គភាពទាំងពីរ សូមថ្លែងអំណរអរគុណដល់ម្ចាស់ជំនួយទាំងអស់ ព្រមទាំងអាជ្ញាធរ រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលផ្សេងៗដែលបានចូលរួមចំណែកផ្នែកហិរញ្ញវត្ថុ នយោបាយ ឬផ្នែកបច្ចេកទេសក្តី ដើម្បីជួយជ្រោមជ្រែងដល់គម្រោងទាំង ១៣ ដែលបានស្នើសុំនៅក្នុងសំណុំរឿង ០០២/០១។

ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់គម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០១ ក្នុងគោលបំណងឲ្យមានការទទួលស្គាល់ជាផ្លូវការដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម កាត់បន្ថយព្យសនកម្ម និងការឈឺចាប់ទាំងឡាយ ដែលជនរងគ្រោះបានជួបប្រទះ និងថែរក្សាការចងចាំជាសមូហភាព និងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ។ ក្នុងករណីមានការផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូង អាចសម្រេចឲ្យមានសំណងផ្លូវចិត្ត និងសំណងសមូហភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសាលក្រមរបស់ខ្លួន ប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបាន


Original EN: 00981924-00981928

បំពេញ ក្នុងនោះរួមមានលក្ខខណ្ឌតម្រូវឲ្យគម្រោងសំណងនីមួយៗ មានឯកសារគ្រប់គ្រាន់ពាក់ព័ន្ធនឹងមូលនិធិពីខាងក្រៅ។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចកាលបរិច្ឆេទកំណត់ត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវតែដាក់ឯកសារ និងព័ត៌មានបន្ថែមទៀតស្ដីពីគម្រោងសំណងដែលខ្លួនបានស្នើសុំនៅក្នុងសំណុំរឿង០០២/០១ រួមមានការធ្វើបច្ចុប្បន្នភាពនៃមូលនិធិជាដើម។

កាលបរិច្ឆេទកំណត់នៅត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ បានកន្លងផុតទៅហើយ។ អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានសេចក្ដីរីករាយ និងសូមប្រកាសថា ជំនួយហិរញ្ញវត្ថុស្ម័គ្រចិត្ត ត្រូវបានទទួលគ្រប់គ្រាន់ សម្រាប់គម្រោងសំណងដែលត្រូវការមូលនិធិដើម្បីអនុវត្ត លើកលែងតែគម្រោងនៅសល់តែមួយប៉ុណ្ណោះ។ សូមមើលតារាងដូចបានភ្ជាប់ជូនជាមួយនឹងសេចក្ដីប្រកាសព័ត៌មាននេះ សម្រាប់ព័ត៌មានស្ដីពីសំណើគម្រោង និងមូលនិធិដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង។

អង្គភាពគាំពារជនរងគ្រោះ គឺជាអង្គភាពផ្លូវការមួយរបស់ អ.វ.ត.ក ហើយមានភារកិច្ចសម្របសម្រួលឲ្យជនរងគ្រោះចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក លែកលែងតែតំណាងផ្លូវច្បាប់។ អង្គភាពនេះក៏មានភារកិច្ចស្វែងរកមូលនិធិ និងជំនួយជ្រោមជ្រែងពីខាងក្រៅ ហើយដោយសហការយ៉ាងជិតស្និទ្ធិជាមួយនឹង សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គភាពនេះមានភារកិច្ចកំណត់ រៀបចំ និងអនុវត្តគម្រោងសំណងផ្សេងៗ។

+++

**ទំនាក់ទំនងអង្គភាពគាំពារជនរងគ្រោះ**

លោក ហង្ស វណ្ណៈ
ប្រធាន អង្គភាពគាំពារជនរងគ្រោះ
សារអេឡិចត្រូនិក៖ hang.vannak@eccc.gov.kh

+++

**ព័ត៌មានទំនាក់ទំនងសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ៖**


លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖neth.pheaktra@eccc.gov.kh

លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

## ឯកសារភ្ជាប់៖ សេចក្តីសង្ខេបអំពីសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០១

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **១. ទិវាជាតិនៃការចងចាំ** | រាជរដ្ឋាភិបាលកម្ពុជា | គម្រោងនេះមានបំណងបង្កើតទិវាជាតិនៃការចងចាំជាផ្លូវការដើម្បីរំឭកដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចនូវជំហរយល់ព្រមជាគោលការណ៍ដើម្បីបង្កើតទិវានេះ។ | មិនត្រូវការមូលនិធិ |
| **២. គំនិតផ្តើមផ្តើមបង្កើតកន្លែងរំឭកវិញ្ញាណក្ខន្ធសាធារណៈ** | អង្គការក្តីករុណា (KdK) និងអង្គការ យុវសន្តិភាព (YfP) | គម្រោងនេះមានបំណងបង្កើតកន្លែងរំឭកវិញ្ញាណក្ខន្ធមួយចំនួនតូច (ប្រហែល៦) ដោយមានសកម្មភាពអប់រំ និងនិយាយរឿងពិតដែលជាប់ពាក់ព័ន្ធ តាមរយៈដំណើរការប្រឹក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី សហគមន៍មូលដ្ឋាន និងភាគីជាប់ពាក់ព័ន្ធផ្សេងទៀតនៅកន្លែងរំឭកវិញ្ញាណក្ខន្ធទូទាំងប្រទេសកម្ពុជា។ | [រង់ចាំម្ចាស់ជំនួយ] |
| **៣. កន្លែងគោរពវិញ្ញាណក្ខន្ធសម្រាប់ជនរងគ្រោះខ្មែរក្រហម៖ "ចំពោះអ្នកដែលបានបាត់បង់ជីវិតទៅហើយ"** | អ៊ីង សេរ៉ា (សិល្បករ) សមាគម ANVAYA ស្ថានទូតបារាំង | គម្រោងនេះមានបំណងបង្កើត និងកសាងបូជនីយដ្ឋានមួយចំនួនស្ថិតនៅកន្លែងរាងត្រីកោណនៅជាប់ស្ថានទូតបារាំងប្រចាំនៅភ្នំពេញ។ បូជនីយដ្ឋានទាំងនេះនឹងរំឭកពីព្រឹត្តិការណ៍ដែលបានប៉ះពាល់ដល់ប្រជាជននៅក្នុងទីក្រុងភ្នំពេញ កាលពីខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលអ្នករស់នៅទីក្រុងនេះ ត្រូវបានខ្មែរក្រហមបង្ខំ ឲ្យចាកចេញចោលពីផ្ទះរបស់ពួកគាត់។ | ▪ សាធារណរដ្ឋបារាំង<br>▪ លោកស្រី Catherine Quére (សមាជិកសភាបារាំង)<br>▪ លោក Avi Assouly (សមាជិកសភាបារាំង)<br>▪ សមាគម ANVAYA<br>▪ OUBASAS<br>▪ ACYC SARL Architectes |



Original EN: 00981924-00981928

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **៤. បូជនីយដ្ឋានសម្រាប់ជនរងគ្រោះខ្មែរក្រហមនៅប្រទេសបារាំង** | សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) ជនរងគ្រោះប្រល័យពូជសាសន៍ខ្មែរក្រហម (VGKR) បូជនីយដ្ឋានសម្រាប់ជនរងគ្រោះប្រល័យពូជសាសន៍ប្រព្រឹត្តឡើងដោយខ្មែរក្រហម (MVGKR) | គម្រោងនេះមានបំណងកសាងបូជនីយដ្ឋានមួយសម្រាប់ជនរងគ្រោះរបបខ្មែរក្រហមដែលរស់នៅប្រទេសបារាំង នៅវត្ត Great Pagoda of Vincennes នៅក្នុងទីក្រុងប៉ារីស ដើម្បីធ្វើជាកន្លែងដែលអ្នកនៅមានជីវិត និងបងប្អូនជនរងគ្រោះ អាចធ្វើពិធីបុណ្យផ្សេងៗ និងរំឭកវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់។ | ▪ គណៈមេធាវីក្រុងប៉ារីស<br>▪ VGKR<br>▪ MVGKR |
| **៥. ការព្យាបាលតាមរយៈការផ្តល់សក្ខីកម្ម** | អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) | គម្រោងនេះ ផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ២០០នាក់ នូវឱកាសចូលរួមការព្យាបាលតាមរយៈការផ្តល់សក្ខីកម្ម ក្នុងនោះពួកគាត់ត្រូវបានអញ្ជើញឱ្យនិយាយអំពីបទពិសោធន៍ឈឺចាប់របស់គាត់ ដោយមានការជួយជ្រោមជ្រែង និងជំនួយពីអ្នកជំនាញសុខភាពផ្លូវចិត្ត ដែលជួយពួកគាត់រៀបចំសក្ខីកម្មរបស់គាត់ ជាទម្រង់លាយលក្ខណ៍អក្សរ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកផ្តល់ជំនួយ អានសាច់រឿងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពិធីបុណ្យសាធារណៈ តាមជំនឿសាសនា និងវប្បធម៌របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ។ | ▪ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ)<br>▪ StiftungKriegstrauma-Therapie<br>▪ អូស្ត្រាលី |

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **៦.ក្រុមជួយខ្លួនឯងដើម្បីស្តារនីតិសម្បទា** | អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) | គម្រោងនេះនឹងបង្កើតក្រុមជួយខ្លួនឯងនៅតាមមូលដ្ឋាន និងមានការសម្របសម្រួលប្រកបដោយវិជ្ជាជីវៈ។ ក្រុមជួយខ្លួនឯង គឺជាសមាគមស្ម័គ្រចិត្ត ដែលជួបជុំគ្នាដើម្បីជួយខ្លួនឯង និងជួយគ្នាទៅវិញទៅមក បង្កើនការយល់ដឹង អភិវឌ្ឍជំនាញដោះស្រាយបញ្ហា និងជម្នះលើការឈឺចាប់ពីអតីតកាល។ | ▪ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ)<br>▪ StiftungKriegstrauma-Therapie<br>▪ អូស្ត្រាលី |
| **៧. ការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងស្តីពីទួលពោធិ៍ជ្រៃ** | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) | ការតាំងបង្ហាញជាអចិន្ត្រៃយ៍ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ នឹងមានដាក់តាំងនៅសារមន្ទីរខេត្តចំនួន ៥ គឺខេត្ត បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ តាកែវ និងស្វាយរៀង។ ការតាំងបង្ហាញនេះដំបូងនឹងផ្តោតលើការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃ ប៉ុន្តែប្រធានបទអាចផ្លាស់ប្តូរតាមពេលវេលា ដើម្បីឆ្លុះបញ្ចាំងពីផ្នែកផ្សេងទៀតនៃបទពិសោធន៍របស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ | ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ) |



Original EN: 00981924-00981928

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **៨. ការតាំងពិព័រណ៍ចល័តស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងស្តីពីទួលពោធិ៍ជ្រៃ** | អង្គការក្តីករុណា (KdK) និងអង្គការ យុវសន្តិភាព (YfP) | គម្រោងនេះគឺជាការតាំងពិព័រណ៍អន្តរសកម្មភាព ដែលអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម អំពី អ.វ.ត.ក និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសការជម្លៀសប្រជាជនដោយបង្ខំ តាមរយៈការតាំងបង្ហាញដោយប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយចម្រុះរួមមានខ្សែភាពយន្ត និងសម្ភារៈរូបភាពសំឡេងផ្សេងទៀតជាមួយនឹងសកម្មភាពចូលរួម ដែលលើកទឹកចិត្តអ្នកទស្សនា ឲ្យបង្កើនចំណេះដឹង និងឆ្លុះបញ្ចាំងស៊ីជម្រៅលើបញ្ហាដែលបានបង្ហាញទាក់ទងនឹងជីវិតផ្ទាល់ខ្លួន និងសង្គមកម្ពុជាបច្ចុប្បន្ន។ | ▪ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ)<br>▪ វិទ្យាស្ថានសម្រាប់ទំនាក់ទំនងបរទេសអាល្លឺម៉ង់ (IFA)<br>▪ Narrowcasters Pty.Ltd |

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **៩. ជំពូកមេរៀនស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃសម្រាប់សៀវភៅមគ្គុទេសន៍សម្រាប់គ្រូបង្រៀន** | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) | ជំពូកបន្ថែមមួយស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងកន្លែងសម្លាប់ទួលពោធិ៍ជ្រៃ នឹងត្រូវបញ្ចូលទៅក្នុងសៀវភៅមគ្គុទេសន៍សម្រាប់គ្រូបង្រៀន៖ ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ (ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩) ដែលត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីអប់រំទាំងអស់ស្តីពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា  ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។ ជំពូកមេរៀននេះ នឹងមានលក្ខណៈអន្តរសកម្មភាព និងផ្តោតលើវិធីសាស្ត្រសិក្សាជាសិស្សមជ្ឈមណ្ឌលគឺក្នុងគោលបំណងសិក្សារួមគ្នាដើម្បីបង្កើតការគិតគូរឲ្យបានគ្រប់ជ្រុងជ្រោយ សកម្មភាពរៀនដោយឯករាជ្យ ឆ្លុះបញ្ចាំង និងពាក់ព័ន្ធជាមួយប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងបទពិសោធន៍របស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។ | សេវាសន្តិភាពស៊ីវិល (GIZ) |



Original EN: 00981924-00981928

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **១០. មណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍នៅភូមិសំរោងក្នុង** | អង្គការយុវសន្តិភាព (YfP) | មជ្ឈមណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍ នឹងត្រូវកសាង និងថែទាំនៅភូមិសំរោងក្នុង ខេត្តបាត់ដំបង ដែលជាទីកន្លែងប្រវត្តិសាស្ត្រមួយនៃការសម្លាប់រង្គាលនៅរបបខ្មែរក្រហម។មជ្ឈមណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍ នឹងមានមណ្ឌលព័ត៌មានមួយកន្លែង សារមន្ទីរមួយកន្លែង និងបន្ទប់ពិភាក្សាមួយកន្លែង។ សហគមន៍នឹងចូលរួមចំណែកជាធនធានមនុស្ស និងហិរញ្ញវត្ថុដើម្បីកសាង និងថែរក្សាមជ្ឈមណ្ឌលសិក្សាដើម្បីសន្តិភាពសហគមន៍ ដែលមានបំណងកែប្រែអតីតកាលអវិជ្ជមានរបស់តំបន់នេះទៅជាអនាគតដ៏មានភាពវិជ្ជមានវិញ តាមរយៈការជំរុញឲ្យសហគមន៍មូលដ្ឋាន និងដើមបណ្តឹងរដ្ឋប្បវេណី កែប្រែតំបន់នេះទៅជាកន្លែងរំឭកវិញ្ញាក្ខន្ធ កន្លែងចងចាំ ពិភាក្សាគ្នា និងអប់រំ។ | ទីភ្នាក់ងារស្វីសដើម្បីអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) |



Original EN: 00981924-00981928

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **១១. សៀវភៅរឿងដើមបណ្តឹងរដ្ឋប្បវេណីដោយមានបង្ហាញរូបភាព** | គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) | គម្រោងនេះនឹងបោះពុម្ពផ្សាយលើកទីពីរនូវសៀវភៅរឿងដើមបណ្តឹងរដ្ឋប្បវេណីរបស់ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ។ គម្រោងបោះពុម្ពសៀវនេះ ធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី ក្លាយជាអ្នកនិទានរឿង ដោយនិយាយរឿងរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ និងជារូបភាពបង្ហាញ។ សៀវភៅនេះនឹងអនុញ្ញាតឲ្យអ្នក ដែលជាធម្មតា ត្រូវបានចាត់ទុកថាមានសំឡេងគ្មានអំណាច និងមិនសូវសំខាន់ ឲ្យមានសំឡេងឡើងវិញ និងមានអារម្មណ៍ថាបានទទួលយុត្តិធម៌តាមរយៈការទទួលស្គាល់។ | សេវាសន្តិភាពស៊ីវិល (GIZ) |
| **១២. ការបោះពុម្ព និងចែកចាយសាលក្រមសំណុំរឿង ០០២/០១** | អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈ | គម្រោងនេះស្វះស្វែងផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីនូវសាលក្រមសំណុំរឿង ០០២/០១ ជាសាលក្រមទាំងស្រុង និងជាសម្រង់សង្ខេប។ សាលក្រមសង្ខេបគឺជាអត្ថបទសង្ខេបជាផ្លូវការរបស់ អ.វ.ត.ក និង/ឬជាអត្ថបទសង្ខេបរៀបចំជាពិសេសដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី ក្រុមគ្រួសាររបស់ពួកគាត់ និងសាធារណជនទូទៅ ងាយទទួលបាន និងចាប់អារម្មណ៍។ សាលក្រមសង្ខេបនឹងពន្យល់ពីសាលក្រម និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយពន្យល់ជាពាក្យសាមញ្ញ។ អត្ថបទនេះ នឹងអបដោយរូបភាពផ្តល់ព័ត៌មាន និងកំសាន្ត ដែលនឹងជួយពន្យល់ពីចំណុចសំខាន់ៗរបស់អត្ថបទ។ | ▪ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ (BMZ)<br>▪ ផ្នែកកិច្ចការសាធារណៈ<br>▪ ឯកអគ្គរដ្ឋទូត David Scheffer |

| ឈ្មោះគម្រោង | ដៃគូគម្រោងសំខាន់ៗ (សម្រាប់អនុវត្ត) | ពណ៌នា | ម្ចាស់ជំនួយបច្ចុប្បន្ន *** |
|---|---|---|---|
| **១៣. ការផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅលើគេហទំព័ររបស់ អ.វ.ត.ក** | អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈ | ឈ្មោះ និងព័ត៌មានអំពីអត្តសញ្ញាណទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវចុះផ្សាយនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ និងនៅលើគេហទំព័ររបស់ អ.វ.ត.ក ដើម្បីជាមធ្យោបាយមួយទទួលស្គាល់ការឈឺចាប់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ហើយទទួលស្គាល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី។ | មិនត្រូវការមូលនិធិ |
| | | មូលនិធិសរុបដែលទទួលបាន៖ | **៧៧០.២៧៥,៨០ ដុល្លារ** |

**ធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ដោយអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**